# សំណូមពរចំពោះលោកអ្នកដែលនៅក្រុងតូក្យូ ទាក់ទងនឹងជំងឺកូវីដ19

○ នៅពេលនេះអ្នកឆ្លងជំងឺ COVID-19 មានចំនួនកើនឡើងខ្លាំង។ គឺគ្រោះថ្នាក់។ គ្រោះថ្នាក់ណាស់។

○ ទីក្រុងតូក្យូនឹងចាត់វិធានការបន្ទាន់ទប់ទល់នឹងការរាលដាលយ៉ាងខ្លាំងនៃមេរោគប្រភេទអូមីក្រុង។
អ្វីដែលសំខាន់នៅពេលនេះ គឺធ្វើយ៉ាងណាកុំឲ្យអ្នកឆ្លងជំងឺកូវីដ19 កើនឡើងម្តងទៀត។

○នេះគឺជាសំណូមពរចំពោះលោកអ្នក សុំឲ្យប្តូររបៀបរស់នៅ ដើម្បីកុំឲ្យឆ្លងជំងឺកូវីដ19 ។

**ពីពេលណាដល់ពេលណា** ពីថ្ងៃទី11 ខែមករា(ថ្ងៃអង្គារ) ម៉ោង 0 ដល់ ថ្ងៃទី31 ខែមករា(ថ្ងៃច័ន្ទ) ម៉ោង12 យប់

## សំណូមពរ

**អ្នករស់នៅក្រុងតូក្យូ**

○ សូមកុំទៅកន្លែងដែលគ្មានបង្អួច ឬកន្លែងដែលខ្យល់មិនអាចចេញចូលបាន។
○ សូមកុំចេញទៅក្រៅនៅម៉ោងដែលមានមនុស្សច្រើន ឬទៅកន្លែងដែលមានមនុស្សច្រើន។
○ សូមកុំនិយាយនៅក្បែរអ្នកដទៃ ឬនិយាយដោយសំលេងខ្លាំងៗ។
○ សូមរក្សាគម្លាតរវាងមនុស្សម្នាក់ទៅមនុស្សម្នាក់។
○ សូមពាក់ម៉ាស់។
○ សូមលាងសម្អាតដៃអោយបានច្រើនដងក្នុង1ថ្ងៃ។
○ នៅពេលបរិភោគអាហារនៅភោជណីយដ្ឋានជាដើម សូមទៅគ្នាតិច ហើយចំណាយពេលអោយខ្លី។
○ សូមជៀសវាងកុំទៅតំបន់មានវិធានការបន្ទាន់/វិធានការអាទិភាព
(កន្លែងដែលមានអ្នកឆ្លងជំងឺ COVID-19 ច្រើន)។
○ នៅពេលមានអាការៈក្តៅខ្លួនជាដើម សូមកុំធ្វើដំណើរកំសាន្ត។
○ បើមានការបារម្ភសូមពិនិត្យ PCR (ការពិនិត្យរកមើលថាបានឆ្លងជំងឺ COVID-19 ឬអត់)។

**អ្នកបើកហាង**

<u>សំណូមពរទាក់ទងនឹងការកាត់បន្ថយម៉ោងបើកហាង/ កម្មវិធី។ល។</u>
*សូមមើលនៅទំព័របន្ទាប់។

一般財団法人
東京都つながり創生財団
Tokyo Metropolitan Foundation "TSUNAGARI"

# កន្លែងអាជីវកម្មសំណូមពរ (ភោជនីយដ្ឋាន ហាងកាហ្វេ ។ល។) ①

<table>
<tr><th>កន្លែង</th><th>ប្រភេទសំណូមពរ</th></tr>
<tr><td>ហាងហូបចុក</td><td rowspan="2">● សូមគោរពតាម "គោលការណ៍ណែនាំនៃប្រភេទអាជីវកម្មនីមួយៗ"។<br><br>※ 
<br><br>● ហាងដែលមានបិទ "តែមបញ្ជាក់ថាបានត្រួតពិនិត្យល្អិតល្អន់ទប់ស្កាត់ការឆ្លងរួច※" នៃគំរោង "TOKYO SUPPORT ត្រួតពិនិត្យល្អិតល្អន់" នៅខាងមុខហាង<br>・ភ្ញៀវក្រុមអាចអង្គុយចូលគ្នាក្នុងតុតែមួយបានត្រឹម 4នាក់។<br>・នៅពេលមានគ្នាចាប់ពី5នាក់ឡើង សូមប្រើ① និង② ដើម្បីឲ្យដឹងថាបានចាក់វ៉ាក់សាំងកូវីដ19 រួច។<br>① កម្មវិធី "TOKYOワクション"<br>② លិខិតបញ្ជាក់ការចាក់វ៉ាក់សាំង (ក្រដាសបញ្ជាក់ថាបានចាក់វ៉ាក់សាំង)<br>・សូមគោរពតាមច្បាប់ចែងនៃគំរោង "TOKYO SUPPORT ត្រួតពិនិត្យល្អិតល្អន់"<br><br>①<br>TOKYO ワクション<br>安心、うれしい。<br>ワクチンでアクション。</td></tr>
<tr><td>កន្លែងកំសាន្ត ។ល។</td></tr>
<tr><td>កន្លែងជួបជុំ ។ល។<br><br>(កន្លែងពិធីអាពាហ៍ពិពាហ៍)</td><td>● ហាងដែលមិនបានទទួល /ឬមិនបានបិទ "តែមបញ្ជាក់ថាបានត្រួតពិនិត្យល្អិតល្អន់ទប់ស្កាត់ការឆ្លងរួច※" នៅខាងមុខហាង<br>・ភ្ញៀវក្រុមអាចអង្គុយចូលគ្នាក្នុងតុតែមួយបានត្រឹម 4នាក់។<br>・ម៉ោងអាចបំរើគ្រឿងស្រវឹង៖ ពីម៉ោង11ព្រឹក ដល់ម៉ោង9 ល្ងាច<br>・ម៉ោងដែលភ្ញៀវអាចយកគ្រឿងស្រវឹងចូលក្នុងហាងបាន៖ ពីម៉ោង11ព្រឹក ដល់ម៉ោង9 ល្ងាច</td></tr>
</table>

# កន្លែងអាជីវកម្មសំណូមពរ (ភោជនីយដ្ឋាន ហាងកាហ្វេ ។ល។) ②

| កន្លែង | ប្រការសំណូមពរ |
|---|---|
| ហាងហូបចុក | ● ហាងដែលមានខារ៉ាអូខេ<br>・សូមកុំឲ្យមនុស្សប្រមូលផ្តុំគ្នាច្រើននៅក្នុងបន្ទប់តែមួយ។<br>・សូមធ្វើឲ្យមានខ្យល់ចេញចូលជាប្រចាំ។<br>・សូមសំលាប់មេរោគលើមីក្រូហ្វូន។<br>・សូមប្រុងប្រយ័ត្នកុំឲ្យឆ្លងជំងឺកូវីដ19។ |
| កន្លែងកំសាន្ត ។ល។ | |
| កន្លែងជួបជុំ ។ល។<br>(កន្លែងពិធីអាពាហ៍ពិពាហ៍) | |



# កន្លែងអាជីវកម្មសំណូមពរ(ផ្សេងទៀត) ①

<table>
<tr><th>កន្លែង</th><th>ប្រការសំណូមពរ</th></tr>
<tr><td>រោងភាពយន្ត មហោស្រព សាលសំដែង។ល។</td><td rowspan="11">
● នៅពេលប្រើខារ៉ាអូខេ<br>
・សូមកុំឲ្យមនុស្សប្រមូលផ្តុំគ្នាច្រើននៅក្នុងបន្ទប់តែមួយ។<br>
・សូមធ្វើឲ្យមានខ្យល់ចេញចូលជាប្រចាំ។<br>
・សូមសំលាប់មេរោគលើមីក្រូហ្វូន។<br>
・សូមប្រុងប្រយ័ត្នកុំឲ្យឆ្លងជំងឺកូវីដ19។<br>
<br>
● ប្រការដែលអាជីវកម្មត្រូវសំណូមពរទៅអតិថិជន<br>
・មិនអាចបរិភោគបាយជុំគ្នាច្រើននាក់បានទេ។<br>
・មិនអាចហូបបាយ ឬគ្រឿងស្រវឹងបានយូរទេ។<br>
● សូមកាត់បន្ថយចំនួនមនុស្សចូលក្នុងហាង ឬទីតាំងអាជីវកម្ម។<br>
● សូមគោរពតាម "គោលការណ៍ណែនាំនៃប្រភេទអាជីវកម្មនីមួយៗ"។<br>
● សូមប្រុងប្រយ័ត្នកុំឲ្យឆ្លងជំងឺកូវីដ19។
</td></tr>
<tr><td>កន្លែងជួបជុំ សាលជួបជុំសាធារណៈ។ល។</td></tr>
<tr><td>សាលពិព័រណ៍ សាលវប្បធម៌។ល។</td></tr>
<tr><td>ផ្សារទំនើប មជ្ឈមណ្ឌលទិញទំនិញ។ល។</td></tr>
<tr><td>សណ្ឋាគារ ផ្ទះសំណាក់(តែកន្លែងជួបជុំ)</td></tr>
<tr><td>ទីលានកីឡាបេស្បល អាគារលេងកីឡា ក្លឹបហាត់ប្រាណ។ល។</td></tr>
<tr><td>សួនកំសាន្ត theme park   សួនកំសាន្តហាងប៉ាឈីងកុ កន្លែងលេងហ្គេម។ល។</td></tr>
<tr><td>សារមន្ទីរ សាលវិចិត្រសិល្បៈ<br>សួនសត្វ។ល។</td></tr>
<tr><td>កន្លែងងូតទឹកសាធារណៈដែលមានបន្ទប់ដោយឡែក<br>ហាងមើលវីដេអូក្នុងបន្ទប់ដោយឡែក។ល។</td></tr>
<tr><td>កន្លែងងូតទឹកប្រណិត ហាងសាឡន។ល។</td></tr>
<tr><td>សាលារៀនបើកបររថយន្ត សាលាបង្រៀនគួរ។ល។</td></tr>
</table>

# កន្លែងអាជីវកម្មសំណូមពរ(ផ្សេងទៀត) ②

<table>
<tr><th>កន្លែង</th><th>ប្រការសំណូមពរ</th></tr>
<tr><td>រោងភាពយន្ត មហោស្រព សាលសំដែង។ល។</td><td rowspan="11">■កន្លែងមិនបញ្ចេញសំលេងខ្លាំង<br>*ចំនួនមនុស្សកំណត់= ចំនួនមនុស្សអាចចូលបាន<br>・ចំនួនមនុស្សកំណត់តិចជាង 5,000 នាក់៖ ត្រឹមចំនួនមនុស្សកំណត់<br>・ចំនួនមនុស្សកំណត់ពី 5,000នាក់ ដល់ 10,000នាក់៖ ត្រឹម 5,000នាក់<br>・ចំនួនមនុស្សកំណត់ចាប់ពី 10,000នាក់ឡើង៖ ត្រឹមពាក់កណ្ដាលនៃចំនួនមនុស្សកំណត់<br>―ក្នុងករណីបានដាក់ជូន "ផែនការសុវត្ថិភាពទប់ស្កាត់ការឆ្លង" ទៅក្រុងតូក្យូ<br>ទោះបីជាមានភ្ញៀវលើសពី 5,000 នាក់ ឬលើសពី50%នៃចំនួនមនុស្សកំណត់ក៏ដោយ ក៏អាចចូលបានដល់ចំនួនមនុស្សកំណត់<br>"ផែនការសុវត្ថិភាពទប់ស្កាត់ការឆ្លង" →<br>■កម្មវិធីដែលមានបញ្ចេញសំលេងខ្លាំង<br>・ត្រឹមពាក់កណ្ដាលនៃចំនួនមនុស្សកំណត់</td></tr>
<tr><td>កន្លែងជួបជុំ សាលជួបជុំសាធារណៈ។ល។</td></tr>
<tr><td>សាលពិព័រណ៌ សាលវប្បធម៌។ល។</td></tr>
<tr><td>ផ្សារទំនើប មជ្ឈមណ្ឌលទិញទំនិញ។ល។</td></tr>
<tr><td>សណ្ឋាគារ ផ្ទះសំណាក់(តែកន្លែងជួបជុំ)</td></tr>
<tr><td>ទីលានកីឡាបេស្បល អាគារលេងកីឡា ក្លឹបហាត់ប្រាណ។ល។</td></tr>
<tr><td>សួនកំសាន្ត theme park សួនកំសាន្តហាងប៉ាឈីងកុ កន្លែងលេងហ្គេម។ល។</td></tr>
<tr><td>សារមន្ទីរ សាលវិចិត្រសិល្បៈ សួនសត្វ។ល។</td></tr>
<tr><td>កន្លែងងូតទឹកសាធារណៈដែលមានបន្ទប់ដោយឡែក ហាងមើលវីដេអូក្នុងបន្ទប់ដោយឡែក។ល។</td></tr>
<tr><td>កន្លែងងូតទឹកប្រណិត ហាងសាឡន។ល។</td></tr>
<tr><td>សាលារៀនបើកបររថយន្ត សាលាបង្រៀនគួរ។ល។</td></tr>
</table>